**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង ខេត្តសៀមរាប**

-សាលក្រមរដ្ឋប្បវេណីលេខ: **១៣ "ឞ "/៦០**
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងរដ្ឋប្បវេណីលេខ: ៥៤
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

-បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ រសៀល នៅសវនាការ នៃសាលាដំបូងខេត្តសៀមរាប។

-បានប្រកាសសាលក្រម នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ រសៀល នៅសវនាការ នៃសាលាដំបូងខេត្តសៀមរាប។

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

លើសំណុំរឿងរដ្ឋប្បវេណី លេខ ៥៤ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ដែលមាន៖

**-ដើមចោទ**ឈ្មោះ [redacted] ចំរើន ភេទស្រី ឆ្នាំ១៩៨៨ ជនជាតិខ្មែរ អាសយដ្ឋាន [redacted]។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**-ចុងចម្លើយ**ឈ្មោះ [redacted] សុជា ភេទប្រុស កើតឆ្នាំ១៩៨៣ ជនជាតិខ្មែរ អាសយដ្ឋាន ភូមិ [redacted]។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ និងចំណុចវិវាទ**

**I- ការទាមទាររបស់ដើមចោទ:**

ដើមចោទបានប្តឹងសុំទាមទារឲ្យតុលាការចេញសាលក្រម ដូចខាងក្រោមៈ

**១**.សុំឲ្យចុងចម្លើយឈ្មោះ [redacted] សុជា ជាអ្នកមានអំណាចមេបាលើកូនចំនួន ០២នាក់ៈ

-កូនទី**១** ឈ្មោះ [redacted]គឹមហ៊ួច ភេទស្រី កើតថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤។

-កូនទី**២** ឈ្មោះ [redacted] ស៊ុនហេង ភេទប្រុស កើតថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧។

**២**.ស្នើសុំឲ្យតុលាការធ្វើការបែងចែកទ្រព្យរួម បំណុលរួម អាហារកាតព្វកិច្ច និងកាតព្វកិច្ចរបស់ភាគីតាមការព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា។

**II-ការសង្ខេបអំពីរឿងក្តី**

ដើមចោទឈ្មោះ [redacted] ចំរើន ភេទស្រី និងចុងចម្លើយឈ្មោះ [redacted] សុជា ភេទប្រុស បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការសុំសាលក្រមលែងលះ និងបានធ្វើកិច្ចព្រមព្រៀងលែងលះបែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ ហើយដើមចោទ ស្នើសុំឲ្យតុលាការសម្រេចបែងចែក ដី និងផ្ទះ ដែលមានវិញ្ញាបនប័ណ្ណបត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០១០៤-០០៥៨ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅ ភូមិដកពោធិ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប តាមកិច្ចព្រមព្រៀងហើយចុងចម្លើយក៏បានយល់ព្រមដែរ។

**III-សេចក្តីថ្លែងការណ៍របស់គូភាគី**

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ក្នុងសំណុំរឿងនេះ កូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងសុំលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] សុជា នៅតុលាការខេត្តសៀមរាប ហើយតុលាការក៏បានចេញសាលក្រម សម្រេចឲ្យកូនក្តីខ្លួន និងចុងចម្លើយឈ្មោះ [redacted] សុជា លែងលះគ្នា និងប្រគល់សិទ្ធិមានអំណាចមេបាលើកូនទាំងពីរនាក់ខាងលើ មកឲ្យកូនក្តីខ្លួន ដោយបញ្ហាទ្រព្យសម្បត្តិ និងបំណុលរួម ផ្សេងៗ គឺកូនក្តីខ្លួន និងចុងចម្លើយ បានព្រមព្រៀងគ្នាខាងក្រៅរួចរាល់ហើយ។ បន្ទាប់ពីតុលាការចេញសាលក្រមរួច ហើយកូនក្តីខ្លួនជាដើមចោទ ចង់លក់ដី និងផ្ទះ ដែលមានវិញ្ញាបនប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០១០៤-០០៥៨ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ដែលជាទ្រព្យសម្បត្តិរួម ដែលចុងចម្លើយព្រមព្រៀងគ្នា ប្រគល់ឲ្យកូនក្តីខ្លួននោះ ដើម្បីលក់យកលុយសងបំណុលរួម ដែលកូនក្តីខ្លួនត្រូវទទួលបន្ទុក ប៉ុន្តែចុងចម្លើយបែជាក្រឡាស់សំដី មិនព្រមទៅផ្តិតមេដៃផ្ទេរកម្មសិទ្ធិ លើដីខាងលើឲ្យទៅអ្នក

ទិញទេ ដោយចុងចម្លើយចង់សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរវិញ និងបានប្ដឹងទៅសាលាឧទ្ធរណ៍ផងដែរ ហើយសាលាឧទ្ធរណ៍ក៏បានចេញ សាលដីកា លេខ ៨១ (គ) ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ សម្រេចតម្កល់សាលក្រម លេខ ១៣ "ឃ" /១២៨ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូង ខេត្តសៀមរាប ទុកជាបានការដដែល។ ពេលនោះ កូនក្ដីខ្លួនក៏បានយល់ព្រមប្រគល់កូនទាំងពីរ ខាងលើ ឲ្យទៅចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបាវិញ ដោយធ្វើបានកិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ រវាងកូនក្ដីខ្ញុំ និងចុងចម្លើយ ដោយមានការចូលរួមពីមេធាវីត្រឹមត្រូវ។ ប៉ុន្តែក្រោយពីធ្វើកិច្ចព្រមព្រៀងនេះរួច ពេលកូនក្ដីខ្លួន ទៅសុរិយោដី ដើម្បីស្នើសុំធ្វើឯកសាររឿងលក់ដីខាងលើ ខាងមន្ត្រីសុរិយោដី គេទាមទារឲ្យចុងចម្លើយទៅផ្ដិតមេដៃផ្ទាល់នៅកន្លែងទៀត ប៉ុន្តែចុងចម្លើយ បែរជាគេចវេសមិនព្រមទៅផ្ដិតមេដៃនៅមុខមន្ត្រីជំនាញ ធ្វើឲ្យកូនក្ដីខ្លួន មិនអាចលក់ដីខាងលើ របស់កូនក្ដីខ្លួន ដើម្បីយកលុយទៅសងបំណុលគេបាន ដូច្នេះ ស្នើសុំតុលាការសម្រេចប្រគល់ដី និងផ្ទះ ដែលមានវិញ្ញាបនប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០១០៤-០០៥៨ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ដូចមានចែងក្នុងកិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ មកឲ្យកូនក្ដីខ្លួន ដើម្បីឲ្យកូនក្ដីខ្លួន អាចលក់ដីនេះ ដើម្បីយកលុយសងបំណុលរួម ដែលកូនក្ដីខ្លួន ត្រូវទទួលបន្ទុក។ ចំពោះកូនទាំងពីរនាក់ខាងលើរបស់កូនក្ដីខ្លួន គឺកូនក្ដីខ្លួន ព្រមប្រគល់សិទ្ធិមានអំណាចមេបាឲ្យទៅចុងចម្លើយវិញ តាមការព្រមព្រៀង។ ដី និងផ្ទះ ដែលមានវិញ្ញាបនប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០១០៤-០០៥៨ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ មិនជាប់បំណុលធនាគារ ឬបំណុលណាមួយ នោះទេ។

ក្រៅពីទ្រព្យសម្បត្តិរួម ដី និងផ្ទះ ខាងលើ ចំពោះទ្រព្យសម្បត្តិរួម បំណុលរួម និងអាហារកាតព្វកិច្ច ផ្សេងទៀត មិនមានបញ្ហាអ្វីនោះទេ និងមិនស្នើសុំបែងចែកទេ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានបានថ្លែងការណ៍ថា កូនក្ដីខ្លួនយល់ព្រមឲ្យតុលាការសម្រេចអនុវត្តតាមកិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ រវាងកូនក្ដីខ្លួន និងដើមចោទ មិនជំទាស់អ្វីទេ គឺទុកសិទ្ធិឲ្យតុលាការសម្រេចតាមនីតិវិធីច្បាប់។ បញ្ជាក់ថា កូនក្ដីខ្លួនមិនបានប្រកែកទ្បាស់សំដីដូចការលើកឡើងរបស់មេធាវីខាងលើនោះទេ គឺកូនក្ដីខ្លួនព្រមប្រគល់ដី និងផ្ទះខាងលើ ឲ្យទៅដើមចោទ ដោយដើមចោទ សន្យាថា នឹងទៅថ្លែងការណ៍នៅសាលាឧទ្ធរណ៍ប្រគល់សិទ្ធិគ្រប់គ្រង

កូនទាំងពីរឲ្យកូនក្តីខ្លួន ប៉ុន្តែដើមចោទបែជាថ្លែងការណ៍សុំឲ្យសាលាឧទ្ធរណ៍តម្កល់សាលក្រម មុន ដដែល ទៅវិញហើយកូនក្តីខ្លួនក៏បានប្តឹងសារទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍រួចហើយដែរ ដើម្បីសុំឲ្យអនុវត្តតាមកិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ បច្ចុប្បន្នសំណុំរឿងនេះ កំពុងដំណើរការនៅតុលាការកំពូលនៅឡើយ។ ហើយជាគុពិត ទ្រព្យសម្បត្តិរួម ដែលប្រគល់ឲ្យដើមចោទ គឺគាត់បានលក់អស់មួយចំនួនហើយ នៅតែដី និងផ្ទះ ខាងលើនោះទេ ដែលមិនទាន់បានផ្ទេរសិទ្ធិ។

VI-**អង្គហេតុដែលគ្មានវិវាទ** ៖ ការទាមទាររបស់ដើមចោទ។

V-**អង្គហេតុដែលមានវិវាទ** ៖ តើការទាមទាររបស់ដើមចោទ ត្រឹមត្រូវ ឬទេ ?

**ការពិនិត្យភស្តុតាង**

I-**ភស្តុតាងជាឯកសាររបស់ដើមចោទ**

**១**.កិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១។

**២**.ឯកសារផ្សេងៗ។

II-**ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

**១**.កិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១។

**២**.ឯកសារផ្សេងៗ។

**សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរ និងការពិនិត្យភស្តុតាងនានា ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តុលាការ **យល់ឃើញថា៖**

**១**-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ចំរើន គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បី តុលាការយកមកពិនិត្យ និងសម្រេចតាមច្បាប់បាន។

**២**-តាមកិច្ចព្រមព្រៀងលែងលះ បែងចែកទ្រព្យសម្បត្តិ និងកំណត់អំណាចមេបា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ និងឯកសារភស្តុតាងក្នុងសំណុំរឿង បញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] ចំរើន និងចុងចម្លើយឈ្មោះ [redacted] សុជា ពិតជាប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវស្របតាមច្បាប់ ហើយបានលែងលះគ្នា និងបានធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ជាមួយគ្នាប្រាកដមែន គប្បី តុលាការពិនិត្យ និងសម្រេចតាមការទាមទាររបស់ដើមចោទ បាន។

៣-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ចុងចម្លើយ និង ឯកសារក្នុងសំណុំរឿង តុលាការយល់ឃើញថា ដី និងផ្ទះ ដែលមានវិញ្ញាបនប័ណ្ណបត្រសំគាល់ម្ចាស់ អចលនវត្ថុ លេខ ១៧១០០១០៤-០០៥៨ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅ ភូមិដកពោធិ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ពិតជាកម្មសិទ្ធិរបស់ដើមចោទ និងចុង ចម្លើយ ហើយដើមចោទ និងចុងចម្លើយ ពិតជាបានព្រមព្រៀងគ្នា ប្រគល់ឲ្យទៅភាគីដើមចោទ ជា ម្ចាស់កម្មសិទ្ធិ ប្រាកដមែន។

៤-ចំពោះការទាមទារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួម បំណុលរួម ផ្សេងទៀត និងកូន ដើមចោទ មិនស្នើសុំបែងចែកទេ ដូច្នេះ តុលាការមិនលើកយកចំណុចនេះ មកពិនិត្យ និងសម្រេចនោះទេ។

៥-ប្រាក់ប្រដាប់ក្តី គប្បី តុលាការសម្រេចជាបន្ទុករបស់ភាគីដើមចោទ។

## សេចក្តីសម្រេចបញ្ចប់

**១-ប្រគល់ឲ្យ** ដើមចោទឈ្មោះ [redacted] ចំរើន ភេទស្រី ជាម្ចាស់កម្មសិទ្ធិ លើដី និងផ្ទះ ដែលមាន វិញ្ញាបនប័ណ្ណបត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០១០៤-០០៥៨ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០១៨ មានទីតាំងស្ថិតនៅ ភូមិដកពោធិ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

-បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រម ចំពោះមុខដើម ចោទ និងចុងចម្លើយ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃ បានទទួល ការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅសៀមរាប, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner